# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

លេខ: ៦៥.សសរ

## សេចក្តីសម្រេច

### ស្តីពីការកែសម្រួលសមាសភាពថ្នាក់ដឹកនាំ ក្នុងលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់

* * ***

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីកាគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦០២/១៩៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៣៦/អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៤ ស្តីពីការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- បានឃើញសេចក្តីសម្រេចលេខ ១៩ សសរ.កបច ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- យោងតាមតម្រូវការចាំបាច់នៃការងារ

## ស ម្រេ ច

**ប្រការ ១ :** ត្រូវបានប្រគល់ភារកិច្ចជូន ឯកឧត្តម ឆេង សារឿន ជាប្រធានលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ជំនួសឯកឧត្តម ឡេង ម៉េងឡុង ដែលបានទទួលភារកិច្ចថ្មី ។

**ប្រការ ២ :** ប្រធានគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងអង្គភាពពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ត្រូវអនុវត្តខ្លឹមសារនៃសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ០៧ ឆ្នាំ ២០០៦

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

សុខ អាន

**កន្លែងទទួល :**

- សមាជិកគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ